MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# សហគមន៍មានសុវត្ថិភាព ៤

adpc

ធ្នូ ២០០៧

# ការពង្រឹងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ និង ការពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះអាសន្ននៅប្រទេសកម្ពុជា

## បង្កើតគោលគំនិតខិតខំប្រឹងប្រែងដើម្បីបញ្ជ្រាប

### ពត៌មានសង្ខេប

ករណីសិក្សានេះ បញ្ជាក់ពីគោលគំនិតមួយដែលអនុវត្តន៍ដើម្បីបញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ទៅក្នុងផែនការ អភិវឌ្ឍន៍របស់មូលដ្ឋាន ។ ដោយផ្អែកលើបទពិសោធន៍របស់គម្រោង " កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) " ដែល អនុវត្តដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) ហើយគាំទ្រជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ធ្វើនៅក្នុងខេត្ត ដែលប្រឈមមុខនឹងគ្រោះទឹកជំនន់ជាងគេ គឺខេត្តព្រៃវែង និងខេត្តកណ្តាល ។ ករណីសិក្សានេះ លើកឡើងពីជំហាននៃការអនុវត្តន៍ដើម្បីទទួលបាននូវការបញ្ជ្រាបប្រកបដោយជោគជ័យ និង ពីមុខងារសំខាន់ៗនៃការយល់ដឹងពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងការតស៊ូមតិនៅក្នុងចំណោមដៃគូអនុវត្តការងារដែលក្នុងនោះមានមន្ត្រី ដែលមិនពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ ក៏បានដើរតួនាទីនៅក្នុងដំណើរការបញ្ជ្រាបនេះដែរ ។

ក្នុងពេលដែលគោលគំនិតមិនទាន់បានឈានដល់ភាពពេញលេញ និងភាពលំអិតពីការបញ្ជ្រាបទៅក្នុងដំណើរការរៀបចំផែនការ អភិវឌ្ឍន៍មូលដាននោះ បទពិសោធន៍ និងមេរៀនសំខាន់ៗនានា ដែលរៀនសូត្របានពីការអនុវត្តការងារត្រូវបានរៀបចំចងក្រងឡើងរួចជាស្រេច។ ទិសដៅទៅខាងមុខបានបង្ហាញឱ្យឃើញនូវមធ្យោបាយដ៏រឹងមាំមួយគឺការបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ឱ្យបានជាក់លាក់ជាមួយនឹងទិសដៅដែលអាចធ្វើឱ្យសម្រេចបានក្នុងពេលឆាប់ៗខាងមុខ។ ។ ករណីសិក្សានេះក៏បានគូសបញ្ជាក់ពីការលំបាកមួយចំនួនដែលបានជួបប្រទះនៅក្នុងដំណើរការនេះ ហើយក៏បានកំណត់កត្តាជោគជ័យសំខាន់ៗជាច្រើនសម្រាប់ធ្វើឱ្យមានប្រសិទ្ធភាពក្នុងការបញ្ជ្រាបនូវគោលគំនិតនេះ ។ យើងទាំងអស់គ្នា ធ្វើការប្រឹងប្រែងបន្តលើការពង្រឹងសមត្ថភាពរបស់មន្ត្រីនៅតាមមូលដ្ឋាន អំពីការគ្រប់គ្រងគ្រោះអាសន្ន ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ នោះការរៀបចំ ផលិតឧបករណ៍ឱ្យបានជាក់លាក់ និងគោលការណ៍ណែនាំនានាសម្រាប់ការបញ្ជ្រាបគោលគំនិត នៅថ្នាក់ឃុំ នៅតែជាកត្តាដ៏ចម្បងសម្រាប់ការប្រឹងប្រែងនៅពេលខាងមុខ ។

### ខ្លឹមសាររឿង

■ គោលគំនិតនៃការបញ្ជ្រាប ២
■ មេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍ ៣
■ ទិសដៅអនុវត្តន៍ពេលខាងមុខ ៣




អស់រយៈពេលជាច្រើនជំនាន់រួចមកហើយ ទឹកជំនន់ទន្លេមេគង្គបានគំរាមកំហែង និងផ្តល់ផលប្រយោជន៍នៅក្នុងជីវភាពរបស់ប្រជាជនកម្ពុជាជាច្រើនជាពិសេសប្រជាជនដែលរស់នៅតាមបណ្តោយប្រទេសដែលស្ថិតនៅតាមដីសណ្តទន្លេមេគង្គ ។ ជារៀងរាល់ឆ្នាំ ទឹកជំនន់ទន្លេមេគង្គបាននាំយកមកនូវដីល្បប់ដែលមានជីជាតិមកស្រោចស្រព្វលើដីរបស់ប្រជាពលរដ្ឋ ដែលពួកគេតែងតែពឹងផ្អែកលើដើម្បីដាំដុះដំណាំសម្រាប់ជីវភាពរបស់ពួកគេ ។ ប៉ុន្តែពេលខ្លះទឹកជំនន់ទន្លេមេគង្គនេះ ក៏បានបង្កឱ្យមានការខូចខាត និងបំផ្លិចបំផ្លាញដល់បណ្តាញប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្ត ជាច្រើនដូចជា សាលារៀន មណ្ឌលសុខភាព, ផ្លូវថ្នល់ និងស្ពានជាដើម ។

ការខូចខាតនិងការបំផ្លិចបំផ្លាញដ៏ច្រើននេះពីគ្រោះទឹកជំនន់បានទាក់ទាញអោយមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីព្រោះវាបាន គំរាមកំហែងដល់សេដ្ឋកិច្ច និងសង្គមជាខ្លាំង ។ ស្ថិតិភាពក្រីក្ររបស់ពលរដ្ឋកម្ពុជាបង្ហាញថាអ្នកក្រីក្រចំនួន ៩០% រស់នៅតាមតំបន់ជនបទ ដែលពួកគេចិញ្ចឹមជីវិតដោយពឹងផ្អែកលើរបរធ្វើស្រែ និងនេសាទត្រី ។ដូច្នេះពួកគេទាំងនេះជាគ្រួសារដែលមានភាពងាយរងគ្រោះបំផុតពីទឹកជំនន់ ។ សូម្បីតែទឹកជំនន់តូចក្តី ក៏វាអាចបំផ្លិចបំផ្លាញទ្រព្យសម្បត្តិពួកគេបានដែរ គឺថាធ្វើឱ្យពួកគេលិចលង់ទៅក្នុងភាពក្រីក្រដ៏ធ្ងន់ធ្ងរ ។ ទាក់ទងនឹងបញ្ហានេះ កម្មវិធីកាត់បន្ថយភាពក្រីក្រនៅតាមដងទន្លេមេគង្គបានរៀបចំដោយផ្ទាល់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ដែលបណ្តាលមកពីឥទ្ធិពលអាក្រក់នៃទឹកជំនន់ ។

## សេចក្តីផ្តើម

ជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមមុខរបស់សហគមន៍ដោយសារគ្រោះទឹកជំនន់ទន្លេមេគង្គ ពិសេសទឹកជំនន់នៅឆ្នាំ ២០០០, ២០០១ និងឆ្នាំ២០០២ គណៈកម្មាការទន្លេមេគង្គ បានចាប់ផ្តើមរៀបចំកម្មវិធីរយៈពេល ៦ ឆ្នាំ លើ " ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ " ដែលមានទិសដៅការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ចដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាន នៃទឹកជំនន់ឱ្យនៅគង់វង្ស ។

គោលបំណងនេះ គឺដើម្បីទទួលបានតាមរយៈការអនុវត្តន៍ផ្នែកសំខាន់ប្រាំ ដែលមានឈ្មោះ : ១-បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់ ២-វិធានការការពារគ្រោះទឹកជំនន់ និងវិធានការជារូបវ័ន្ត ៣-ការសម្របសម្រួលបញ្ហាគ្រោះទឹកជំនន់នៅតាមព្រំដែន ៤-ការពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ ៥-ការគ្រប់គ្រងដីធ្លី ។

ការអនុវត្តន៍ផ្នែកទី ៤ របស់កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់លើ " កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ដែលអនុវត្តន៍ដោយគណៈកម្មាការទន្លេមេគង្គ (MRC) ហើយគាំទ្រជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) និងទទួលជំនួយឧបត្ថម្ភថវិកាពីភ្នាក់ងារសហប្រតិបត្តិការជំនួយបច្ចេកទេសអន្តរជាតិប្រទេសអាឡឺម៉ង់ (GTZ) ។

ទិសដៅរបស់គម្រោងនេះគឺធ្វើឱ្យ "ប្រព័ន្ធគ្រប់គ្រងភាពអាសន្ននៅក្នុងបណ្តាប្រទេសនៅតាមដងទន្លេមេគង្គមានសមត្ថភាពដោះស្រាយបានយ៉ាងមានប្រសិទ្ធភាពនឹងគ្រោះមហន្តរាយទឹកជំនន់ទន្លេមេគង្គ"។ លទ្ធផលទាំងមូលរបស់គម្រោងនេះ គឺបង្កើនសមត្ថភាពរបស់អាជ្ញាធរស៊ីវិលនៅគ្រប់លំដាប់ថ្នាក់, អ្នកគ្រប់គ្រងភាពអាសន្ន និង សហគមន៍នៅក្នុងការងារត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយទឹកជំនន់។

គម្រោងនេះចាប់ផ្តើមនៅឆ្នាំ២០០៤ មានរយៈពេល៣ឆ្នាំហើយបញ្ចប់នៅឆ្នាំ ២០០៧ ។ វាអនុវត្តន៍នៅក្នុងខេត្តពីរដែលប្រឈមមុខជាងគេនៅក្នុងប្រទេសកម្ពុជា គឺខេត្តកណ្តាល និងខេត្តព្រៃវែង ។ ស្រុកពីរនៅក្នុងខេត្តនីមួយៗត្រូវបានជ្រើសរើសក្នុងការអនុវត្តន៍សាកល្បង គឺមានស្រុកពាមជរ និងស្រុកស៊ីធរកណ្តាល ក្នុងខេត្តព្រៃវែង និងនៅក្នុងខេត្តកណ្តាល គឺស្រុកល្វាឯម និងស្រុកលើកដែក ។ ស្រុកទាំងបួននេះ ស្ថិតនៅលើដីសណ្តទន្លេមេគង្គ និងជាស្រុកដែលប្រឈមមុខជាងគេនឹងគ្រោះទឹកជំនន់នៅក្នុងខេត្តនីមួយៗ។

លទ្ធផលដំបូងរបស់គម្រោងនេះ គឺការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងថ្នាក់ស្រុក ។ មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយ






អាស៊ី(ADPC)បានសម្របសម្រួលដំណើរការនេះដោយផ្តល់ជំនួយបច្ចេកទេស និងគាំទ្រដៃគូអនុវត្តន៍នៅមូលដ្ឋានគ្រប់កម្រិត។ ដោយយោងទៅលើរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា ជនបង្គោលនៅក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក ត្រូវបានតែងតាំងឱ្យធ្វើជាអ្នកអនុវត្តន៍ដ៏សំខាន់នៃសកម្មភាពគម្រោង។

ការចូលរួមយ៉ាងសកម្មរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) បានចាប់ផ្តើមតាំងពីការរៀបចំបង្កើតគម្រោងទឹកជំនន់នេះដំបូង ដោយមានការតែងតាំងជនបង្គោល និងការបង្កើតអង្គភាពគាំទ្រជំនួយបច្ចេកទេស(TSU)នៅក្នុង NCDM ដែលវានឹងផ្តល់សេវាគាំទ្រទៅដល់អង្គភាពថ្នាក់ខេត្ត នៅពេលខាងមុខ ។

អាស្រ័យដោយមានកិច្ចប្រជុំ និងសិក្ខាសាលាពិភាក្សា និងរៀបចំផែនការជាច្រើន កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងថ្នាក់ស្រុកបានរៀបចំបញ្ចប់នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៦ ។ កម្មវិធីនេះបង្ហាញនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយនៃការត្រៀមបង្ការ និងការគ្រប់គ្រងគ្រោះអាសន្ននៅក្នុងខេត្ត និងស្រុកគោលដៅ ដូចដែលពួកគេបានរៀបចំបាននូវកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ជាលើកដំបូង ។

### ១.គោលគំនិតនៃការបញ្ជ្រាប

ក្រោយពីកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងស្រុកនេះបានរៀបចំរួចមកលោក ហ៊ុល ចំរើន ជនបង្គោលនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត នៃខេត្តព្រៃវែង បានកត់សម្គាល់ឃើញថា មានការរីកចំរើនខ្លាំងណាស់លើការសម្របសម្រួល និងទំនាក់ទំនង ការងាររវាងមន្ទីរពាក់ព័ន្ធជាច្រើននៅក្នុងខេត្តព្រៃវែងនេះ។ ប៉ុន្តែគាត់ក៏មានការព្រួយបារម្ភផងដែរ ដោយសារមានការខ្វះធនធានហិរញ្ញវត្ថុ និងសម្ភារៈ ដែលវានឹងអាចជាឧបសគ្គច្រើនចំពោះការអនុវត្តន៍កម្មវិធី ហើយបើគ្មានធនធាន ការយកចិត្តទុកដាក់ក្នុងការធ្វើនឹងចុះអន់ថយ។

ដូច្នេះវាមិនមានការអ្វីដែលគួរឱ្យភ្ញាក់ផ្អើលទេ ដែលសិក្ខាសាលាត្រួតពិនិត្យលើកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់បានរៀបចំនោះ ហើយដែលមន្ត្រីនៅតាមមូលដ្ឋានបានបង្ហាញនូវបញ្ហាដូចគ្នានេះដែរ ពិសេសលើបញ្ហាថា បើផែនការនេះបានរៀបចំរួចហើយវានឹងដំណើរទៅមុខ និងមាននិរន្តរភាពបាន

លោក ហ៊ុល ចំរើន ជនបង្គោលគណៈ
កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង
(PCDM) បានមានប្រសាសន៍ថា : "...ក្នុងការឱ្យដើរតួនាទីនៅក្នុងការសម្រប
សម្រួលពួកគេឱ្យរៀបចំផែនការទឹកជំនន់ មន្ទីរពាក់ព័ន្ធទាំងនោះសង្ឃឹមថា PCDM
ជាអ្នកជួយផ្គត់ផ្គង់ខាងធនធានហិរញ្ញវត្ថុសម្រាប់ប្រើប្រាស់ដើម្បីអនុវត្តន៍
ផែនការត្រៀមបង្ការគ្រោះទឹកជំនន់...ចំពោះខ្ញុំបញ្ហានេះបញ្ជាក់ឱ្យ ឃើញពីតម្រូវការ
សម្រាប់ការបញ្ជ្រាបបញ្ហាកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ទៅក្នុងផែនការ
អភិវឌ្ឍន៍របស់បណ្តាមន្ទីរពាក់ព័ន្ធទាំងអស់នេះ" ។

អ្វីជាការបញ្ជ្រាប?

ពាក្យ បញ្ជ្រាប ជាពាក្យប្រៀបធៀបមួយទៅនឹងខ្សែទឹក ដែលហូរចាក់ទៅក្នុងទន្លេ ហើយវានឹងហូរបែកសាយទៀតដោយមិនមាន ការបាត់បង់ទៅណាឡើយ ។

ដូចនេះ "ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ" សំដៅដល់ដំណើរការនៃការដាក់បញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការកិច្ចការគោលនយោបាយអភិវឌ្ឍន៍ និងការអនុវត្តជាក់ស្តែង។ មានន័យថា ជាការពង្រីក និងពង្រឹងនូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដើម្បីអោយវាក្លាយជាកិច្ចការអនុវត្តន៍ធម្មតា ហើយអាចប្រើប្រាស់នៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់អង្គភាពណាមួយ។

*- Mainstreaming Disaster Risk Reduction, Tearfund, 2005*

យ៉ាងដូចម្តេច។ ការកង្វះធនធាន ពិសេសនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា បានបង្កើតជាក្តីសង្ស័យជាច្រើនពីមន្ត្រីនានានៅមូលដ្ឋានថា ផែនការរបស់ពួកគេនឹងដំណើរការទៅមុខរហូតដែរឬទេ ។

ចម្លើយមួយទៅនឹងបញ្ហាដែលបានពិភាក្សានៅក្នុងសិក្ខាសាលាគឺការបញ្ជ្រាប។ តម្រូវការសម្រាប់បញ្ចូលផែនការត្រៀមបង្ការគ្រោះទឹកជំនន់ទៅក្នុងផែនការអភិវឌ្ឍន៍ ត្រូវបានលើកយកមកពិភាក្សា ។រីឯការរៀបចំដំបូងនៃកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នទឹកជំនន់ មិនមានការបញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទេ ការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយរបស់មន្ត្រីថ្នាក់ខេត្ត បានធ្វើឱ្យអង្គការ ADPC មានការចាប់អារម្មណ៍យ៉ាងខ្លាំង ដែលវាបានគាំទ្រពួកគេយ៉ាងខ្លាំងសម្រាប់ការបញ្ជ្រាបនេះ ។

ក្រោយរយៈពេលមួយឆ្នាំ នៃការពិភាក្សាជាលើកដំបូងនៅក្នុងសិក្ខាសាលាត្រួតពិនិត្យ គោលគំនិតនៃការបញ្ចូលគ្រោះទឹកជំនន់នេះ បានកំណត់ដូចខាងក្រោមនេះ :

## ការបង្កើនការយល់ដឹង : បង្កើននូវការយល់ដឹងជាទូទៅមួយលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់

វគ្គបណ្តុះបណ្តាល និងសកម្មភាពរៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ដែលបានរៀបចំនៅពេលចាប់ផ្តើមកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់(FEMS) បានធ្វើឱ្យគោលបំណងនៃការបញ្ជ្រាបមានជោគជ័យយ៉ាងល្អប្រសើរ ព្រោះវាបានបង្កើតនូវការយល់ដឹងដ៏ទូលំទូលាយនៃការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ក្នុងការរៀបចំគោលគំនិតលើការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទូទៅ។

មន្ត្រីនៅតាមមូលដ្ឋានមិនអាចរំពឹងថានឹងចូលរួមយ៉ាងពេញលេញ និងដំណើរការបញ្ជ្រាបនេះដោយខ្លួនឯងទេ ប្រសិនបើពួកគេមិនមានការយល់ដឹងពីទំនាក់ទំនងនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ពួកគេផ្ទាល់ ។ ដើម្បីបន្តការងារនោះមន្ត្រីត្រូវតែយល់ ឬក៏អាចទទួលយកបាននូវគោលគំនិត និងគោលការណ៍នៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ដែលជាឧបសគ្គដ៏ចំបងនៅក្នុងដំណើរការបញ្ជ្រាបនេះ ។

## វិមជ្ឈការ : បរិយាកាសដែលអំណោយផល

កម្មវិធីវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលមានឈ្មោះថា គម្រោងគាំទ្រកិច្ចអភិវឌ្ឍន៍បែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) បានផ្តល់នូវបរិយាកាសដ៏ល្អសម្រាប់គោលគំនិតបញ្ជ្រាបដែលនឹងត្រូវបានរៀបចំឡើងនេះ។ នេះមានន័យថា គំនិតបញ្ជ្រាបអាចធ្វើការភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលយើងបាន។ PSDD នេះផ្តោតលើការពង្រឹង ការគ្រប់គ្រង, ការចូលរួម និងការទទួលខុសត្រូវនៅថ្នាក់ឃុំ ដោយការផ្តល់ឱ្យពួកគេនូវការទទួលខុសត្រូវ និងគ្រប់គ្រងលើការអភិវឌ្ឍន៍របស់ខ្លួនពួកគេ ដែលរួមមានការទទួលបានធនធានខាងផ្នែកហិរញ្ញវត្ថុ ទោះបីជាមានទំហំតិចតួចក៏ដោយ ។

ការផ្សារភ្ជាប់គ្នាទាំងក្រៅនិងក្នុងប្រព័ន្ធជាមួយកម្មវិធីPSDD នៅក្នុងខេត្តគោលដៅពីរនេះបានបង្កើតឡើងភ្លាមៗ និងបានពង្រឹងជាបន្តបន្ទាប់។ មន្ត្រីសម្របសម្រួល និងមន្ត្រីរដ្ឋបាលរបស់កម្មវិធីបានទទួលវគ្គបណ្តុះបណ្តាលលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងគ្រោះទឹកជំនន់ និងទំនាក់ទំនងរបស់វាជាមួយនឹងការអភិវឌ្ឍន៍។

ការចូលរួមនិងការយល់ដឹងរបស់ពួកគេនៅក្នុងការងារបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយបានពង្រឹងថែមទៀតតាមរយៈការចូលរួមជាប្រចាំនៅក្នុងសិក្ខាសាលាជាច្រើន ដែលរៀបចំក្រោមគម្រោង FEMS នេះ និងតាមរយៈទំនាក់ទំនងដ៏រឹងមាំរបស់ពួកគេជាមួយនឹងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (DCDM) ។

លោក យ៉ាំ សារឹង
ប្រធានទីប្រឹក្សាកម្មវិធីខេត្ត
បានមានប្រសាសន៍ថា : " យើងគាំទ្រយ៉ាងខ្លាំងដល់ការ
បញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុង
ផែនការអភិវឌ្ឍន៍ថ្នាក់ស្រុក និងឃុំ ពីព្រោះយើងបានមើលឃើញថា ការធ្វើ
ព្រងើយកន្តើយ នឹងធ្វើឱ្យយើងមានផលប៉ះពាល់ដល់ខ្លួនយើងដោយសារគ្រោះ
ទឹកជំនន់... ដូចជានៅក្នុងស្រុកល្វាឯម ផ្លូវដែលបានសាងសង់ពេលរដូវប្រាំង
ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងនៅពេលរដូវទឹកជំនន់" ។



## ការជួយគាំទ្រ : ពីគោលគំនិតទៅជាសកម្មភាព

មានមូលដ្ឋានគ្រឹះជាច្រើនសម្រាប់សកម្មភាពបញ្ជ្រាបដែលបានមកពីកិច្ចប្រឹងប្រែងគាំទ្ររបស់មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត និង ស្រុក ដោយមានជំនួយបច្ចេកទេស និង គាំទ្រពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)។ កត្តាសំខាន់នោះ គឺការចូលរួមរបស់មន្ត្រីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) និងស្រុក (DCDM) ដែលមកពីខេត្តកណ្តាល, ព្រៃវែង, តាកែវ និងខេត្តស្វាយរៀងនៅក្នុងសិក្ខាសាលារៀបចំផែនការថ្នាក់ជាតិរបស់កម្មវិធី PSDD ដែលមានក្រសួងផែនការជាប្រធាន ។

គោលបំណងសិក្ខាសាលានេះ គឺដើម្បីស្វែងរកនូវបទពិសោធន៍និងស្វែងយល់ពីមេរៀនល្អៗពីការអនុវត្តន៍រយៈពេលប្រាំឆ្នាំដំបូងរបស់កម្មវិធីវិមជ្ឈការរបស់រាជរដ្ឋាភិបាល គឺកម្មវិធីសិលា “SEILA” ដែលបច្ចុប្បន្ននេះហៅថាកម្មវិធី PSDD ។ នៅក្នុងកម្មវិធី PSDD នេះមន្ត្រីនៅមូលដ្ឋានបានស្នើសុំឱ្យក្រសួងផែនការធ្វើការបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ស្រុក និងឃុំដែលជាវិស័យទី៦នៃផែនការអភិវឌ្ឍន៍ (នៅផ្នែកខាងលើនៃសកម្មភាពជាអាទិភាពអភិវឌ្ឍន៍ទាំង ៥ ដែលមាននៅក្នុងគម្រោងការរៀបចំផែនការអភិវឌ្ឍន៍បច្ចុប្បន្ន) ឬជាបញ្ហាស្នូល ។

ក្រសួងផែនការបានឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីទាំងនេះ ហើយក៏បានសហការជាមួយនឹងអង្គការ ADPC ដើម្បីធ្វើការយ៉ាងជិតស្និទ្ធ ជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយជាតិ ដើម្បីដាក់ជាអនុសាសន៍លើរបៀបនៃការបញ្ចូលឱ្យមានដំណើរការឈានឆ្ពោះទៅមុខ ។

កត្តាដែលប្រសើរនោះគឺថា កម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយបានស្វែងរកឃើញនូវការគាំទ្រលើការបញ្ជ្រាបនេះពី ឯកឧត្តម ហ៊ូ តាំងអេង អនុរដ្ឋលេខាធិការ ក្រសួងផែនការ និងជាអតីតអគ្គលេខាធិការ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) ដែលបានសំដែងការគាំទ្រនិងនៅតែបន្តគាំទ្រយ៉ាងខ្លាំងទៅដល់ការបញ្ជ្រាបកម្មវិធី និង សកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍។

កិច្ចប្រឹងប្រែងសំខាន់មួយទៀតត្រូវបានប្រើប្រាស់ដើម្បីដាក់ដំណើរការបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយជាមួយនឹងអង្គភាពអភិវឌ្ឍន៍ដ៏មានឥទ្ធិពលនៅក្នុងខេត្ត គឺគណៈកម្មាធិការប្រតិបត្តិរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តដែលដឹកនាំដោយ អភិបាលខេត្ត, អភិបាលស្រុក និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រតិបត្តិការនៅក្នុងខេត្ត។

## វគ្គបណ្តុះបណ្តាល និងការផ្តល់បច្ចេកទេស : ការបង្កើនចំណេះដឹង និងការកសាងជំនាញ

ពេលដែលមូលដ្ឋានគ្រឹះសម្រាប់បញ្ជ្រាបត្រូវបានរៀបចំយ៉ាងរឹងមាំ សកម្មភាពជាច្រើនបានសំដៅតែទៅលើការរៀបចំវគ្គបណ្តុះបណ្តាល និងការផ្តល់បច្ចេកទេស។ វគ្គបណ្តុះបណ្តាល និងការផ្តល់បច្ចេកទេសត្រូវបានរៀបចំយ៉ាងសមស្រប ដោយការបញ្ចូលប្រធានបទនៃការបញ្ជ្រាបការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយជាមេរៀននៅក្នុងកម្មវិធីជាបន្តបន្ទាប់នៃសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលដែលរៀបចំនៅក្រោមកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់។ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលទាំងអស់នេះមានដូចជា :

### សិក្ខាសាលា ស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដល់មន្ត្រីរៀបចំផែនការអភិវឌ្ឍន៍របស់កម្មវិធី PSDD

បុគ្គលិកថ្នាក់ខេត្ត និងស្រុក របស់ PSDD ចំនួន ១៥០នាក់ បានទទួលនូវការបណ្តុះបណ្តាលលើកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ។ ជនបង្គោលមកពី NCDM និងមន្ត្រីរបស់អង្គការ ADPC ជាអ្នករៀបចំនូវកម្មវិធីនៃវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមសហគមន៍(CBFM) ដែលតម្រូវឱ្យមន្ត្រីរៀបចំផែនការទាំងអស់ចូលរួម ហើយវគ្គនេះរៀបចំនៅក្នុងឃុំគោលដៅ និងត្រូវអនុវត្តន៍ដោយសមាជិកក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM)។

### ការយល់ដឹងពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍

ក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនេះ អង្គការADPC បានសហការជាមួយនឹងក្រសួងផែនការ (MoP) រៀបចំវគ្គបណ្តុះបណ្តាលមួយសម្រាប់មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត និងស្រុក ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ និងត្រឹមត្រូវ លើដំណើរការរៀបចំផែនការអភិវឌ្ឍន៍នេះ។

ឃុំគឺជាកម្រិតរដ្ឋបាលថ្នាក់ទាប ដែលតម្រូវឱ្យមានការរៀបចំនូវដំណើរការរៀបចំផែនការ និងរៀបចំការងារវិមជ្ឈការនៅទីនោះ។ ដូច្នេះកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ក៏ត្រូវរៀបចំនៅទីនោះផងដែរ។ នៅក្រោមដំណើរការនេះPSDD បានផ្តល់ជំនួយបច្ចេកទេសដល់ឃុំនីមួយៗដូចនេះពួកគេអាចរៀបចំផែនការអភិវឌ្ឍន៍ឃុំ (CDP) រយៈពេលប្រាំឆ្នាំ ដែលបែងចែកជាផែនការវិនិយោគឃុំសង្កាត់ (CIP) ប្រចាំឆ្នាំ។ បន្ទាប់មក CIP ត្រូវ



បានធ្វើការពិភាក្សា និងចាត់សកម្មភាពជាអាទិភាពនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។ យោងលើការអនុម័តនៃកម្មវិធីវិនិយោគឃុំសង្កាត់ សកម្មភាពត្រូវត្រួតពិនិត្យ និងវាយតម្លៃត្រូវបានអនុវត្តន៍ ដើម្បីផ្តល់ឧទាហរណ៍សម្រាប់ការអនុវត្តន៍ និងដើម្បីណែនាំពីការអនុវត្តន៍ការងារអភិវឌ្ឍន៍របស់ឃុំនៅពេលអនាគត។

ចំណុចគួរកត់សម្គាល់ឃើញថា ការបញ្ច្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ គួរតែចាប់ផ្តើមធ្វើនៅជំហានដំបូងនៃដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ដោយធ្វើការបញ្ចូលពត៌មាន និងការវិភាគលើមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះទៅក្នុងឯកសារសេដ្ឋកិច្ចរបស់ឃុំ។ បើគ្មានការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ និងការវិភាគគ្រោះភ័យនេះទេវានឹងមានការពិបាកប្រមើលមើលលើការរៀបចំផែនការបន្ទាប់នៃការកំណត់សេចក្តីត្រូវការ និងសកម្មភាពអាទិភាពរបស់សហគមន៏ និងពិបាកក្នុងការដោះស្រាយបញ្ហាកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ។

វាក៏បានបង្ហាញផងដែរថា វិធីសាស្រ្ត និងឧបករណ៏សំខាន់ៗ ត្រូវបានប្រើប្រាស់ដោយកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងការត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៏ រួមទាំងវិធីសាស្រ្តចូលរួមពីសហគមន៏ជាដើម ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ឱ្យអាជ្ញាធរឃុំ និងប្រជាពលរដ្ឋសហគមន៏អាចធ្វើការពិភាក្សាលើគោលគំនិតកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងបរិបទនៃការអភិវឌ្ឍន៏សហគមន៏ទាំងមូល ។

ដោយមានចំណេះដឹងគ្រប់គ្រាន់លើជំហាន និងដំណើរការសំខាន់ៗនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៏មូលដ្ឋាន មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយអាចកំណត់នូវការងារ និងពេលវេលានៃសកម្មភាពបញ្ជ្រាបនេះបាន។ បន្ទាប់មកការរៀបចំសកម្មភាពនេះបានដាក់បញ្ចូលទៅក្នុងមេរៀននៃវគ្គបណ្តុះបណ្តាល



ដល់អ្នកអប់រំ (ToT) ស្តីពីការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមសហគមន៏ដែលចូលរួមដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក (PCDM, DCDM),និងមន្ត្រីនៃមន្ទីរពាក់ព័ន្ធដទៃទៀត។ ការរៀបចំសកម្មភាពទាំងនេះក៏បានប្រើប្រាស់ នៅក្នុងវគ្គបណ្តុះបណ្តាលដែលបានរៀបចំនៅក្នុងឃុំគោលដៅជាច្រើនផងដែរ ។

ម្យ៉ាងវិញទៀត នីតិវិធីបញ្ជ្របកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៏ឃុំនេះ ក៏បានផ្សព្វផ្សាយដោយមន្ត្រីក្រសួងផែនការ នៅក្នុងកិច្ចប្រជុំជាប្រចាំមួយនៃវេទិកាកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា (CDRR)។ វេទិកានេះមានទាំងអង្គការជាតិ និងអន្តរជាតិដែលអនុវត្តន៏គម្រោងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា។ វេទិកានេះ តែងតែរៀបចំជាប្រចាំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)។



## សិក្ខាសាលាត្រួតពិនិត្យលើការរៀបចំផែនការ

ក្រោយពីរយៈពេលមួយឆ្នាំ នៃការបង្កើតកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងស្រុក សិក្ខាសាលាមួយបានរៀបចំសម្រាប់សមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក ធ្វើការត្រួតពិនិត្យលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ហើយធ្វើការកំណត់នូវចំណុចខ្សោយ និងចំណុចខ្លាំង នៅក្នុងដំណើរការរៀបចំផែនការនេះ ហើយរៀបចំផែនការសកម្មភាពបន្តសម្រាប់អនុវត្តន៍កម្មវិធីនេះ។ មន្ត្រីមូលដ្ឋានមានការព្រួយបារម្ភពីសមត្ថភាពអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ដែលបានបង្កើតឡើង និងតម្រូវការសម្រាប់បញ្ចូលផែនការនេះទៅក្នុងផែនការអភិវឌ្ឍន៍ក៏ត្រូវការពិភាក្សាកាន់តែខ្លាំងឡើង ។

សិក្ខាសាលានេះបាននាំទៅរកការកំណត់បាននូវនីតិវិធីល្អៗដើម្បីបញ្ចូលសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់នៅក្រោមផែនការត្រៀមបង្ការគ្រោះទឹកជំនន់ដែលបានរៀបចំនោះ ទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ។

គម្រោងនិងសកម្មភាពកាត់បន្ថយ និងត្រៀមបង្ការគ្រោះទឹកជំនន់ត្រូវបានកំណត់រួចហើយ នៅក្នុងផែនការវិនិយោគឃុំសង្កាត់ ដែលនឹងគាំទ្រដោយ PCDM/DCDM នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។ គម្រោងនិងសកម្មភាពចំនួន ២៦នៅក្នុងខេត្តព្រៃវែង និងខេត្តកណ្តាល ត្រូវបានកំណត់ថាជាគម្រោងដែលទាក់ទងនឹងបញ្ហាគ្រោះទឹកជំនន់។ គំរោងទាំងនេះ មានដូចជាគំរោងត្រៀមបង្ការ (ការកំនត់ និងការថែរក្សាទីទួល សំរាប់មនុស្ស និងសត្វ, ទូក, ការការពារការបាក់ច្រាំងទន្លេ, ការរៀបចំប្រព័ន្ធផ្តល់ពតិមានជាមុន, សុខភាព និងអនាម័យ, ការចាក់ថ្នាំការពារសត្វ, ក្រុមសង្គ្រោះសហគមន៍), គំរោងឆ្លើយតប (វគ្គបណ្តុះបណ្តាលលើកិច្ចការស្រាវជ្រាវ និងរុករកសង្គ្រោះ, ទូកសំរាប់ជំលៀស និងថ្នាំពេទ្យ), គំរោងស្តារ និងជួសជុលឡើងវិញ (ហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ ដែលមានផ្លូវ, ស្ពាន, ប្រលាយ រំលូទឹក, ទំនប់ទឹក, ទីទួលសុវត្ថិភាព និងគំរោងគាំទ្រការស្តារឡើងវិញ) ។

## វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមសហគមន៍សម្រាប់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ

នៅពេលឃុំនីមួយៗ នៅក្នុងប្រទេសកម្ពុជារៀបចំបោះឆ្នោតជ្រើសរើសអាណត្តិថ្មី នូវគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM) ដូចនេះគណៈកម្មាធិការទាំងនោះមានតែមុខតំណែងប៉ុណ្ណោះលើមុខងារគ្រោះមហន្តរាយ ឬទឹកជំនន់។ ដូច្នេះគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក, សមាជិកមកពីមន្ទីរពាក់ព័ន្ធក្នុងខេត្ត និងបុគ្គលិក PSDD នៅមូលដ្ឋាន ដែលសុទ្ធតែបានទទួលវគ្គបណ្តុះបណ្តាលនេះរួចហើយបានរៀបចំវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមមូលដ្ឋាននេះ (CBFM) ដល់គណៈកម្មាធិការថ្មីៗទាំងនោះនៅ ក្នុងឃុំគោលដៅទាំងបួន។

នៅពេលខាងមុខ នៅក្នុងសិក្ខាសាលាថ្នាក់ឃុំទាំងនេះការបញ្ចូលបញ្ហាកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ទៅក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ នឹងក្លាយជាប្រធានបទសំខាន់មួយសម្រាប់ការពិភាក្សា។ ការដាក់បញ្ចូលនៃទិន្នន័យនិងព័ត៌មានដែលបានរៀបចំបានតាមរយៈវិធីសាស្ត្រវាយតម្លៃតាមការចូលរួម (ដូចជាផែនទីមុខសញ្ញាគ្រោះថ្នាក់, ការវិភាគលើសមត្ថភាព និងភាពងាយរងគ្រោះ, ការចាត់ថ្នាក់ធនធានជាដើម) ត្រូវបានប្រើប្រាស់ដោយអ្នកធ្វើផែនការលើការងារអភិវឌ្ឍន៍ និងអ្នកធ្វើផែនការលើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ដើម្បីបញ្ចូលទៅក្នុងផែនការឃុំ, ហើយធ្វើការវិភាគ និងចាត់ជាអាទិភាពពីតម្រូវការរបស់សហគមន៍។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM) មិនដូចគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត និងស្រុកទេ ព្រោះពួកគេមិនបានទទួលការណែនាំ និងការគាំទ្រក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ឃុំណាមួយដោយខ្លួនពួកគេផ្ទាល់ឡើយ ។ ដោយហេតុថា ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ត្រូវចាប់ផ្តើមធ្វើពីផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ដូចនេះការខ្វះផែនការត្រៀមបង្ការនេះ គឺជាចំណុចដែលខ្សោយបំផុតនៅក្នុងគោលគំនិតបញ្ជ្រាបនេះ។ នៅក្នុងបរិបទប្រទេសកម្ពុជា និងបរិបទនៃគោលគំនិតបច្ចុប្បន្ននៅក្នុងប្រព័ន្ធវិមជ្ឈការ ការពង្រឹងសមត្ថភាពឃុំលើការរៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់គឺការងារសំខាន់។



## ការចែករំលែកមេរៀន និងបទពិសោធន៍

ការចែករំលែកគំនិត និងបទពិសោធន៍ជាច្រើន លើការបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ត្រូវបានផ្តល់ទៅឱ្យដៃគូអនុវត្តន៍ និងមន្ត្រីអង្គភាពជាច្រើនតាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។

សិក្ខាសាលាទាំងនេះមានពីរ គឺសិក្ខាសាលាចែករំលែកមេរៀន និងបទពិសោធន៍ថ្នាក់ជាតិ និងមួយទៀត គឺសិក្ខាសាលាថ្នាក់តំបន់លើគោលគំនិតថ្មីលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់នៅក្នុងអាងទន្លេមេគង្គ ដែលបានរៀបចំនៅប្រទេសថៃ។ការចូលរួមរបស់មន្ត្រី មូលដ្ឋាននៅក្នុងសិក្ខាសាលាដែលមិនមែនឧបត្ថម្ភដោយកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមផងដែរ ។

## ២.មេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍

- សកម្មភាពនៃឆន្ទៈនយោបាយរបស់មន្ត្រីជាន់ខ្ពស់ និងមន្ទីរពាក់ព័ន្ធនានា គឺជាកត្តាដែលត្រូវការជាអាទិភាព ដើម្បីគោលគំនិតបញ្ជ្រាបទទួលបានជោគជ័យ ។ បើគ្មានឆន្ទៈចូលរួមនិងភាពជាម្ចាស់ការរបស់មន្ត្រី និង ភ្នាក់ងារពាក់ព័ន្ធ លើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងវិស័យការងាររបស់ពួកគេទេ ការបញ្ជ្រាបនេះក៏មិនអាចមាននិរន្តរភាពបានដែរ ។
- ការកំណត់ស្វែងរកការជួយគាំទ្ររបស់មូលដ្ឋាន ឬ "ការទ្រទ្រង់កម្មវិធី" ដែលប្រកបដោយជោគជ័យនោះ នឹងអាចមានប្រសិទ្ធភាពយ៉ាងខ្លាំងអាស្រ័យទៅលើភាពជាម្ចាស់ការរបស់ដៃគូអនុវត្តន៍នៅមូលដ្ឋាន និងវាធ្វើឱ្យមានការសម្របសម្រួលដ៏ល្អប្រសើរលើដំណើរការរៀបចំផែនការនេះ ។
- ប្រព័ន្ធវិមជ្ឈការ បានផ្តល់បរិយាកាសដ៏ល្អមួយសម្រាប់ការបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ ហើយប្រព័ន្ធវិមជ្ឈការនេះត្រូវបានអនុវត្តន៍យ៉ាងល្អនៅឯថ្នាក់មូលដ្ឋាន ដែលការទទួលខុសត្រូវ និងធនធានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ត្រូវបានផ្តល់និងផ្ទេរ ។ នៅក្នុងបរិបទនៅក្នុងប្រទេសកម្ពុជាការអនុវត្តន៍វិមជ្ឈការបែបនេះត្រូវបានធ្វើនៅឯថ្នាក់ឃុំ ។
- ប្រព័ន្ធវិមជ្ឈការ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយហើយវាក៏មិនអាចកើតឡើង ដោយគ្មានកិច្ចប្រឹងប្រែងនៅក្នុងសកម្មភាពការបង្កើនការយល់ដឹង, ការគាំទ្រ តស៊ូមតិ និង ការកសាងសមត្ថភាពបានដែរ ។
- កិច្ចប្រឹងប្រែងក្នុងការកសាងសមត្ថភាពមូលដ្ឋានលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ផ្តោតសំខាន់តែទៅលើអង្គភាពគ្រប់គ្រងគ្រោះមហន្តរាយប៉ុន្តែដើម្បីឱ្យការបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយកើតមានឡើងនោះវាសំខាន់ណាស់ដែលសមត្ថភាពតាមស្ថាប័នលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយត្រូវបានពង្រឹងដូចគ្នាទាំងអស់ទៅដល់អង្គភាព និងមន្ទីរពាក់ព័ន្ធដទៃទៀតដូចជា មន្ទីរសុខាភិបាល, កសិកម្ម, កិច្ចការនារីជាដើម ។
- ការបញ្ជ្រាបនេះគួរតែរៀបចំដោយប្រើប្រាស់នីតិវិធីតាំងពីថ្នាក់ក្រោមដល់ថ្នាក់លើ គឺថាតាមរយៈការបញ្ជ្រាបទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍នៅមូលដ្ឋាន និង ព្រមទាំងតាមរយៈការបញ្ជ្រាបទៅក្នុងផែនការរបស់មន្ទីរ និងវិស័យនានារបស់មន្ទីរពាក់ព័ន្ធ ។
- ការតៀងគរធនធានដែលមានកំណត់នៅតាមតំបន់ជនបទរបស់ប្រទេសកម្ពុជា ការបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ គឺនៅតែជាជំរើសធនធានដ៏យូរអង្វែងបំផុតសម្រាប់កម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ។

## ៣.ទិសដៅអនុវត្តន៍នៅពេលខាងមុខ

គោលគំនិតលើការបញ្ចូលកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយបានចាប់ផ្តើមនៅក្នុងដំណាក់កាលចុងក្រោយរបស់គម្រោង នៃកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ដូច្នេះវាត្រូវបន្តធ្វើការអនុវត្តន៍តទៅទៀត ។ នៅពេលដែលទទួលបាននូវលទ្ធផលមួយចំនួនមកសំណូមពរនិងអនុសាសន៍ក៏មានច្រើនដែរ ពីដៃគូអនុវត្តន៍នានាដែលគួរពិចារណានៅពេលដែលអនុវត្តន៍បន្តនូវគោលគំនិតបញ្ជ្រាបនេះពេលខាងមុខ ។

មេរៀន និងបទពិសោធន៍សំខាន់ៗពីការបញ្ជ្រាបជាច្រើនដែលទទួលបានពីកម្មវិធី FEMS គួរតែយកទៅបកប្រែ និងដាក់បញ្ចូលទៅក្នុងគោលការណ៍ណែនាំសម្រាប់សកម្មភាពបញ្ជ្រាបណាមួយ ដល់មន្ត្រីថ្នាក់ឃុំ ស្រុក និងខេត្ត ដែលរួមមាន ទម្រង់ត្រួតពិនិត្យ និងវាយតម្លៃជាដើម ។ ក្នុងលក្ខណៈបែបនេះ សកម្មភាពផ្សព្វផ្សាយបន្តទៅដល់ឃុំដទៃទៀត នឹងអាចធ្វើឱ្យប្រសើរឡើងបាន ។

ការរៀបចំផែនការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់នៅថ្នាក់ឃុំ គួរតែបញ្ជាក់និងពន្យល់ឱ្យបានច្បាស់ពីទំនាក់ទំនងនៃផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ថ្នាក់ឃុំ ទៅនឹងផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ថ្នាក់ខេត្ត-ស្រុក និងគួរបញ្ជាក់ផងដែរ ពីការបញ្ចូលផែនការឃុំនេះទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន ។

ការឧបត្ថម្ភគាំទ្រដល់សកម្មភាព និងគម្រោងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយថ្នាក់ឃុំ ដែលបានកំណត់ និងចាត់ជាអាទិភាពតាមរយៈយន្តការរបស់កម្មវិធី PSDD (សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក) ដើម្បីផ្តល់ឱ្យអង្គភាពមូលដ្ឋាននូវហេតុផល និងការលើកទឹកចិត្តដើម្បីបន្ត និងពង្រីកបន្ថែមទៀតលើការបញ្ចូលនៃការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍របស់ពួកគេ ។

ការចូលរួម និងការគាំទ្រយ៉ាងសកម្មរបស់មជ្ឈមណ្ឌល ADPC ដោយសហការជាមួយដៃគូអនុវត្តន៍នៅក្នុងប្រទេសកម្ពុជា សម្រាប់បញ្ជ្រាបការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងនៅជួររាជរដ្ឋាភិបាល នឹងអាចពង្រឹងសមត្ថភាពថ្នាក់ខេត្ត និងមូលដ្ឋាន បានយ៉ាងប្រសើរលើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយបានរយៈពេលវែង ហើយការបញ្ជ្រាបនេះគួរតែស្វែងរកយុទ្ធសាស្ត្រល្អៗ បន្ថែមទៀតសម្រាប់អនុវត្តន៍ ។


## សេចក្តីថ្លែងអំណរគុណ

សហគមន៍មានសុវត្ថិភាព សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីអ្នកទាំងអស់ដូចខាងក្រោមក្នុងការរៀបចំចងក្រងករណីសិក្សានេះ :

លោក Aloysisus Rego ប្រធានក្រុម ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក Thanongdeth Insisiengmay ប្រធានគ្រប់គ្រងកម្មវិធី ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ADPC, ប្រទេសកម្ពុជា
លោក Aslam Perwaiz ប្រធានគ្រប់គ្រងគំរោង, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក ជុំ វុទ្ធី , ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិ, ADPC, ប្រទេសកម្ពុជា
លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី, ADPC, ប្រទេសកម្ពុជា
លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង, ADPC, ប្រទេសកម្ពុជា
អ្នកស្រី Xanthe Cobb, អ្នកនិពន្ធ
លោក លឹម តារា, អ្នករចនាអត្ថបទ

សហគមន៍មានសុវត្ថិភាព ជាឈុតនៃករណីសិក្សា ដែលបានដកស្រង់យកអនុវត្តន៍ល្អៗមកបង្ហាញទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយ គ្រោះមហន្តរាយ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលនិង អង្គការក្រៅរដ្ឋាភិបាល សំដៅកាត់បន្ថយភាពងាយរងគ្រោះ និង គ្រោះភ័យនៃគ្រោះមហន្តរាយរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ។

ករណីសិក្សានេះ មានទិសដៅផ្តល់ដល់អ្នកធ្វើការសំរេចចិត្ត អ្នកធ្វើផែនការអភិវឌ្ឍន៍ អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយ អ្នកដឹកនាំសហគមន៍ និង អ្នកអប់រំនានានូវគំនិតច្នៃប្រឌិត ឧបករណ៍ យុទ្ធសាស្ត្រ និង ជំរើសគោលនយោបាយនានា ដែលបានដកស្រង់ពីបទពិសោធន៍ពិតប្រាកដ ការអនុវត្តន៍ល្អៗ និង មេរៀនល្អៗ ដែលទទួលបានពីតំបន់អាស៊ីប៉ាស៊ីហ្វិច ទាក់ទង នឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះ មហន្តរាយ និង កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ព្រមទាំងកសាងអោយបាននូវភាពជួយខ្លួនឯងរបស់សហគមន៍ និង ធ្វើអោយមានសង្គម ដែលមានការត្រៀមបង្ការគ្រោះមហន្តរាយបានល្អប្រសើរ ។

ក្នុងដំណាក់កាលទី១នេះ ករណីសិក្សាមួយចំនួនត្រូវបានរៀបចំក្រោមផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយ គ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ។ ដូចនេះករណីសិក្សានេះបានផ្តោតសំខាន់តែទៅលើការគ្រប់គ្រងគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមតំបន់ភូមិសាស្ត្រនៃប្រទេស ជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលមានប្រទេស កម្ពុជា ឡាវ ថៃឡង់ដ៏និងវៀតណាម ។ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍និង ការអនុវត្តន៍ល្អៗដែលទទួលបាន ពីបណ្តាប្រទេសដទៃទាក់ទងនឹងគ្រោះ មហន្តរាយធម្មជាតិនឹងត្រូវដាក់បញ្ចូលបន្ថែមនៅពេលក្រោយៗទៀត ។

គោលបំណងនៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មាធិការទន្លេមេគង្គ គឺដើម្បីការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ច ដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់មាន ៥ផ្នែកសំខាន់ៗដូចខាងក្រោមៈ

ផ្នែកទី ១ : បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់

ផ្នែកទី ២ : វិធានការណ៍បែបរចនាសម្ព័ន្ធ និងការទប់ស្កាត់គ្រោះទឹកជំនន់

ផ្នែកទី ៣ : ការសំរបសំរួលបញ្ហាគ្រោះទឹកជំនន់ឆ្លងដែន

ផ្នែកទី ៤ : ការពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ផ្នែកទី ៥ : ការគ្រប់គ្រងដី

ផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) នេះ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គ ដោយជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងឧបត្ថម្ភថវិកាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ) ដែលបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៤ ដល់ខែមេសា ឆ្នាំ២០០៨។ តំបន់គោលដៅរបស់គំរោងនេះមាននៅក្នុងប្រទេសកម្ពុជា និងវៀតណាម ដែលប្រទេសនីមួយៗយកខេត្ត២ និងស្រុក៤ ជាតំបន់គោលដៅ ។ ដៃគូររបស់គំរោងនេះ មានគណៈកម្មាធិការជាតិទន្លេមេគង្គ, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរមូលដ្ឋានប្រចាំខេត្ត ស្រុក និងឃុំរបស់គេ, មន្ទីរ-ការិយាល័យពាក់ព័ន្ធ, ស្ថាប័នផ្សេងៗ, កាកបាទក្រហម, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ។ល ។

ចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) បានសំរេចសមិទ្ធិផលដូចខាងក្រោមៈ

១-កម្មវិធិត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានបង្កើត និងអនុវត្ត

២-សមត្ថភាពថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិត្រូវបានបង្កើនក្នុងការគាំទ្រទៅលើដំណើរការបង្កើត និងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការបណ្តុះបណ្តាលនៅកំរិតមូលដ្ឋាន ស្តីការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមសហគមន៍, ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ, ការរុករកនិងសង្គ្រោះ, ការគ្រប់គ្រងគ្រោះអាសន្នដល់កុមារតូចៗ, ការបង្ហាត់ហែលទឹកដល់កុមារ ។ល ។ ហើយនិងការចូលរួមទៅក្នុងការអនុវត្តគំរោង ។

៣-ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈស្តីពីវិធានការសុវត្ថិភាពគ្រួសារថ្នាក់មូលដ្ឋានត្រូវបានបង្ហាញ រួមមានការផ្សព្វផ្សាយដល់គ្រូបង្រៀន និងកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់នៅតាមសាលារៀន, ការកំណត់ពីតួរនាទីការចាំបាច់របស់ស្ត្រីមេគ្រួសារ, ការសំដែងសិល្បៈ, ចាប៊ីដងវែង, ការចែកផ្សព្វផ្សាយសៀវភៅទឹកជំនន់, ផ្ទាំងរូបភាព ជាដើម ។

៤-ការចែករំលែកបទពិសោធន៍ថ្នាក់មូលដ្ឋាន និងតំបន់ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលាជាតិ និងតំបន់ ព្រមទាំងធ្វើការបែងចែកឯកសារបទពិសោធន៍ល្អៗជាច្រើន ។

---

**សំរាប់ពត៌មានបន្ថែម អ្នកអានអាចទាក់ទងអាស័យដ្ឋានដូចខាងក្រោម**


អ្នកសំរបសំរួលកម្មវិធីគ្រប់ គ្រងនិងកាតបន្ថយគ្រោះទឹកជំនន់
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.mrcmekong.org

ប្រធានគ្រប់គ្រងកម្មវិធី, មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.adpc.net email : antonio@adpc.net


---

**ដៃគូរគំរោង**

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)
ប្រអប់សំបុត្រលេខ ៦១០១ អគារលេខ ១៨ បានស៊ីថានេនូវ ខ័ណ្ឌស៊ីកុតថាបុង
ក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣ ទូរសារ: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org វ៉ិបសាយ: http://www.mrcmekong.org

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
ផ្ទះលេខ ២៣ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ទូរសារ: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh វ៉ិបសាយ: http://www.camnet.com.kh/cnmcs

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) (២៣) ៨៨២ ០៤៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល (PCDM)
ឃុំដើមមាន ស្រុកតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៤២៥៥៥៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង (PCDM)
ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៩៤៤ ៥៤៦

adpc

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)
SM Tower, ជាន់ ទី២៤, ៩៧៩/៦៩, Paholyothin, Samsen Nai, Phayathai,
ក្រុងបាងកក, ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ២២ ៩៨ ០៦៨១ ដល់ ៩២
ទូរសារ: (៦៦) ២២ ៩៨ ០០១២ ដល់ ១៣
អ៊ីម៉ែល: adpc@adpc.net វ៉ិបសាយ: www.adpc.net


ឧបត្ថម្ភដោយ:

gtz Partner for the Future Worldwide on behalf of: Federal Ministry for Economic Cooperation and Development

ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាឡឺម៉ង់ (GTZ)